**ធម្មទេសនារបស់លោកអភិបាល អូលីវីយេ**
**អធិដ្ឋានជាមួយអដ្ឋិធាតុរបស់សន្ត លូវីស និងសន្តី ហ្សេលី ម៉ាតាំង**
**បឹងទំពុន ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៩**

## សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះមនុស្សលោក

**អត្ថបទទី១៖ ភីលីព ២,៦-១១**

ព្រះអង្គបានលះបង់អ្វីៗទាំងអស់ មកយកឋានៈជាទាសករ ព្រះអង្គបានទៅជាមនុស្សដូចមនុស្សឯទៀតៗ ហើយក៏រស់នៅក្នុងភាពជាមនុស្សសាមញ្ញដែរ។ ភីល ២,៧

**ដំណឹងល្អ៖ យ៉ូហាន ៣,១៣-១៧**

ព្រះជាម្ចាស់ស្រឡាញ់មនុស្សលោកខ្លាំងណាស់ ហេតុនេះហើយបានជាព្រះអង្គប្រទានព្រះបុត្រាតែមួយរបស់ព្រះអង្គមក ដើម្បីឲ្យអស់អ្នកដែលជឿលើព្រះបុត្រា មានជីវិតអស់កល្បជានិច្ច គឺមិនឲ្យគេវិនាសឡើយ។ យហ ៣,១៦

បងប្អូនជាទីស្រឡាញ់!

យើងអង្គុយនៅមុខព្រះកាយព្រះគ្រីស្ត នៅមុខធាតុរបស់សន្ត លូវីស និងសន្តី ហ្សេលី ជាពេលវេលាដើម្បីផ្ញើជីវិតរបស់យើង គ្រួសាររបស់យើងទៅព្រះជាម្ចាស់។ យើងដឹងថា ព្រះជាម្ចាស់ស្រឡាញ់យើងយ៉ាងខ្លាំងពីដើមរៀងមក នៅពេលព្រះបិតាបានបង្កើតពិភពលោក នៅថ្ងៃទីប្រាំមួយបានបង្កើតយើងជាបុរសនិងស្ត្រី។ គម្រោងការណ៍របស់ព្រះជាម្ចាស់ គឺឲ្យបុរសនិងស្ត្រីទៅជារូបកាយតែមួយ ផ្លូវតែមួយ និងបង្កើតកូនដើម្បីឲ្យមានគ្រួសារ មានឪពុក មានម្តាយ មានកូន និងឲ្យគ្រួសារនេះគ្រប់គ្រងពិភពលោកទាំងមូល។ អ្វីៗទាំងអស់ ដែលព្រះបិតាបានបង្កើតពីថ្ងៃទីមួយដល់ថ្ងៃទីប្រាំ មានទឹកសមុទ្រ ភ្នំ រុក្ខជាតិ សត្វទាំងឡាយ... ព្រះជាម្ចាស់ប្រគល់ឲ្យគ្រួសារជាអ្នកគ្រប់គ្រង។ ពីដើមរៀងមក គម្រោងការណ៍របស់ព្រះជាម្ចាស់គឺបង្កើតគ្រួសារដ៏សុខសាន្ត គ្រួសារដំបូងគឺអាដាំ អេវ៉ា កាអ៊ីន អាបែល និងសិត ជាគ្រួសារដែលពោរពេញដោយសេចក្តីសុខ និងជាគ្រួសារដែលចូលនៅក្នុងទុក្ខលំបាកដែរ ដោយសារអំពើបាបដែលចេញពីចិត្តលោភលន់ចេញពីចិត្តច្រណែន។ ប៉ុន្តែ ព្រះជាម្ចាស់ស្រឡាញ់យើងនិងណែនាំឲ្យគ្រួសារនីមួយៗអាចទៅមុខតទៅទៀត រហូតដល់ព្រះអង្គចងសម្ពន្ធមេត្រី ទំនាក់ទំនងរវាងព្រះជាម្ចាស់និងមនុស្សយើងគឺសម្ពន្ធមេត្រី ដូចទំនាក់ទំនងរវាងប្តីនិងប្រពន្ធ នៅថ្ងៃទទួលអគ្គសញ្ញាអាពាហ៍ពិពាហ៍ចងសម្ពន្ធមេត្រីរវាងគ្នានិងគ្នានៅក្នុងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ដើម្បីរួមរស់ជាផ្លូវតែមួយអស់មួយជីវិតទាំងគ្រាសប្បាយទាំងគ្រាអាសន្ន។

និមិត្តនៃទំនាក់ទំនងរវាងមនុស្សយើងនិងព្រះជាម្ចាស់គឺសម្ពន្ធមេត្រី គឺអភិបូជា ព្រះជាម្ចាស់ស្រឡាញ់មនុស្សលោកយ៉ាងខ្លាំង ព្រះជាម្ចាស់មិនចាប់កំណើតជាមនុស្សទទេ ប៉ុន្តែព្រះអង្គបានជ្រើសរើសគ្រួសារដ៏វិសុទ្ធគឺព្រះនាងម៉ារី និងលោកយ៉ូសែប ដើម្បីស្វាគមន៍ព្រះបុត្រាយេស៊ូដែលជាព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ព្រះអង្គ។ សម្ពន្ធមេត្រី បានផ្សះផ្សារសាជាថ្មីជាសម្ពន្ធមេត្រីអស់កាលជានិច្ចរវាងមនុស្សលោកនិងព្រះជាម្ចាស់ ដោយសារព្រះយេស៊ូគ្រីស្តដែលចាប់កំណើតជាមនុស្សនៅក្នុងក្រុមគ្រួសារដ៏វិសុទ្ធ។ សញ្ញាសម្គាល់ដំបូងបង្អស់ ដែលព្រះយេស៊ូបានសម្ដែង គឺនៅក្នុងពិធីមង្គលការ ជាក្រុមគ្រួសារមួយដែលកំពុងកើតថ្មីដោយអគ្គសញ្ញាអាពាហ៍ពិពាហ៍ ជាក្រុមគ្រួសារដែលពោរពេញដោយអំណរសប្បាយ ដែលមានឪពុកម្ដាយលោកតាលោកយាយ បងប្អូនប្រុសស្រី និងភ្ញៀវជាច្រើនបានចូលរួមដើម្បីអបអរសាទរគូស្រករថ្មី។ ជាពេលវេលាហ្នឹង ដែលព្រះយេស៊ូបានជ្រើសរើសដើម្បីបង្ហាញសញ្ញាសម្គាល់ដ៏អស្ចារ្យមុនគេបង្អស់។ យប់នេះ យើងនឹកឃើញដល់ប្រវត្តិសាស្ត្រនៃការសង្គ្រោះ ដែលជាប្រវត្តិសាស្ត្រនៃគ្រួសារដែលព្រះជាម្ចាស់បានជ្រើសរើសជាអាទិភាព។ នៅពេលនេះ យើងនៅស្ងៀមស្ងាត់ ដោយសម្លឹងមើលព្រះកាយព្រះគ្រីស្ត ដោយទូលអង្វរព្រះយេស៊ូគ្រីស្តដែលចាប់កំណើតជាមនុស្សនៅក្នុងគ្រួសារមួយ។ តាមរយៈសន្ត លូវីស និងសន្តី ហ្សេលី តាមរយៈសន្តី តេរេសា នៃព្រះកុមារយេស៊ូ យើងផ្ញើជីវិតរបស់យើងទៅលើព្រះជាម្ចាស់ ជីវិតយើងជាគ្រួសារដែលមានគោលដៅទៅជាក្រុមគ្រួសារដ៏វិសុទ្ធ។ ទោះបីយើងមិនស្គាល់ផ្លូវយ៉ាងច្បាស់ ប៉ុន្តែយើងមានគោលបំណងនេះនៅក្នុងដួងចិត្តរបស់យើង ដូច ហ្សេលី ដែលគាត់ធ្លាប់និយាយថា "**ខ្ញុំមិនដឹងធ្វើយ៉ាងមេចដើម្បីទៅជាសន្តី ប៉ុន្តែនៅក្នុងចិត្តខ្ញុំ ខ្ញុំចង់ធ្វើជាសន្តីមែនទែន**"។ យប់នេះយើងផ្ញើជីវិតរបស់យើងជាគ្រួសារដោយទូលអង្វរព្រះអង្គឲ្យព្រះអង្គប្រទានព្រះពរ ប្រទានសេចក្តីសុខ ជាពិសេសប្រទានសេចក្តីសង្ឃឹម ដោយសារយើងស្គាល់យ៉ាងច្បាស់អំពីទុក្ខលំបាកនៃជីវិតជាគ្រួសារ អំពីបញ្ហាដែលយើងជួប។ យើងអធិដ្ឋានសម្រាប់គ្រួសារទាំងអស់ ជាពិសេសគ្រួសារដែលបាក់បែកគ្នា គ្រួសារដែលមើលមិនឃើញផ្លូវនៃសេចក្តីសុខ គ្រួសារដែលពោរពេញដោយទុក្ខលំបាកនៅលើទឹកដីប្រទេសកម្ពុជាក៏ដូចជានៅក្នុងពិភពលោក ដោយសារសង្គ្រាម ដោយសារការស្អប់គ្នា ដោយសារការច្រណែនគ្នា ដោយសារការមិនយល់ចិត្តគ្នា។ យើងទូលអង្វរអស់ពីដួងចិត្ត ឲ្យព្រះអង្គប្រទានពរតាមរយៈសន្ត លូវីស និងសន្តី ហ្សេលី និងក្រុមគ្រួសារដ៏វិសុទ្ធ ដើម្បីឲ្យជីវិតរបស់យើងជាគ្រួសារជាឪពុកម្តាយ ជាកូន ជាបងប្អូន ជាលោកតាលោកយាយ ដើម្បីឲ្យព្រះសហគមន៍របស់យើងជាមហាគ្រួសាររបស់ព្រះគ្រីស្ត រកឃើញសេចក្តីពិត រកឃើញផ្លូវនៅក្នុងជីវិត រកឃើញជីវិតពោរពេញដោយសេចក្តីសង្ឃឹម។ អាម៉ែន៕